ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំត្រីមាសទី១ ឆ្នាំ២០១៤

## I- សភាពការណ៍រួម

ក្នុងត្រីមាសទី១ ឆ្នាំ២០១៤នេះ ស្ថានភាពអាកាសធាតុនៅតែទទួលរងឥទ្ធិពលពីជ្រលងសម្ពាធទាបខ្សោយ ផ្ទៃមេឃមានពពកតិចទៅមធ្យម ខ្យល់បក់មកពីទិសអាគ្នេយ៍និងអាចមានភ្លៀងកក់ខែនៅតំបន់មួយចំនួននៃប្រទេសកម្ពុជា។ មកទល់ពេលនេះការងារបង្កបង្កើនផលដំណាំស្រូវប្រាំងឆ្នាំ២០១៣-២០១៤ បានបញ្ចប់ ក្នុងនោះដំណាំស្រូវសម្រេចបាន ១២៦,៣៤% នៃផែនការដាំដុះ។ ទន្ទឹមនឹងនេះ ការងារប្រមូលផលដំណាំស្រូវរដូវប្រាំងបានបញ្ចប់ជាស្ថាពរ ដោយសម្រេចបាន៩៩,៧៥% នៃផ្ទៃដីអនុវត្តបាន។

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ ដំណាំស្រូវរដូវប្រាំងឆ្នាំ២០១៣-២០១៤

-ផ្ទៃដីភ្ជួររាស់សរុបចំនួន៥៤៨.៦០៩ហិកតា លើសឆ្នាំមុនចំនួន១.៥៩៣ហិកតា

-ផ្ទៃដីសាបសរុបចំនួន៤.៨៧២ហិកតា តិចជាងឆ្នាំមុនចំនួន៥៤១ហិកតា

-ផ្ទៃដីសន្ទូងនិងពង្រោះសរុបចំនួន៤៨៤.៥៣៩ហិកតា ស្មើនឹង១២៦,៣៤ភាគរយ នៃផែនការ៣៨៣.៥៣០ហិកតា តិចជាងឆ្នាំមុនចំនួន១០.៩៦៨ហិកតា

-ការងារប្រមូលផលស្រូវរដូវប្រាំងសម្រេចបានលើផ្ទៃដីចំនួន៤៨៣.៣០៩ហិកតា ដោយទទួលបានបរិមាណផលសរុបចំនួន២.១១២.៩០៦តោន និងទិន្នផលជាមធ្យមចំនួន៤,៣៧២តោនក្នុងមួយហិកតា។

#### ១.២ ដំណាំរួមផ្សំ

**ផ្ទៃដីសម្រេចបានចំនួន៨៣.១៥១ហិកតា ស្មើនឹង១៩០,៩៦ភាគរយ នៃផែនការសរុប៤៣.៥៤៤ហិកតា តិចជាងឆ្នាំមុន ៣៧.២០០ហិកតា ក្នុងនោះមាន៖**

-ផ្ទៃដីដាំពោតចំនួន២០.៨១២ហិកតា (ក្នុងនោះពោតក្រហមចំនួន១៥.២៥៨ហិកតា) តិចជាងឆ្នាំមុន២១.៩០៩ហិកតា

-ផ្ទៃដីដំឡូងឈើចំនួន២៥.៥៩៨ហិកតា តិចជាងឆ្នាំមុន៥.០២៩ហិកតា

-ផ្ទៃដីដំឡូងជ្វាចំនួន២.៨៤១ហិកតា តិចជាងឆ្នាំមុន៥៣០ហិកតា

-ផ្ទៃដីបន្លែគ្រប់មុខចំនួន២២.៥៩៣ហិកតា តិចជាងឆ្នាំមុន៣.៩៥៥ហិកតា

-ផ្ទៃដីសណ្តែកបាយចំនួន១១.៣០៧ហិកតា តិចជាងឆ្នាំមុន៥.៧៧៧ហិកតា ។

#### ១.៣ ដំណាំឧស្សាហកម្ម

ផ្ទៃដីសម្រេចបាន១៧.៦០៥ហិកតា ស្មើនឹង៨៧,៨៣ភាគរយ នៃផែនការសរុប ២០.០៤៤ហិកតា តិចជាងឆ្នាំមុន ៥៨៧ហិកតា ក្នុងនោះមាន៖

-ផ្ទៃដីសណ្តែកដីចំនួន២.៨២០ហិកតា លើសឆ្នាំមុន១៩៨ហិកតា



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
№ 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ២១១ ៣៥១ / ២១១ ៣៥២ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 211 351/211 352, Fax : (855) 23 - 217 320

-ផ្ទៃដីសណ្តែកសៀងចំនួន២៦ហិកតា តិចជាងឆ្នាំមុន២.៥៦៩ហិកតា
-ផ្ទៃដីល្ងចំនួន២.១២៦ហិកតា តិចជាងឆ្នាំមុន១៦៦ហិកតា
-ផ្ទៃដីអំពៅចំនួន៥.៩៦០ហិកតា លើសឆ្នាំមុន២.០៧៥ហិកតា
-ផ្ទៃដីក្រចៅចំនួន៤១ហិកតា លើសឆ្នាំមុនចំនួន១ហិកតា
-ផ្ទៃដីថ្នាំជក់ចំនួន៦.៦៣២ហិកតា តិចជាងឆ្នាំមុន១២៦ហិកតា។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| **I-ចម្ការកៅស៊ូកសិឧស្សាហកម្មរដ្ឋ** | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ១៤២,៩៩ | - |
| | **សរុប I** | **៤០៦,៦០** | **៣៤៤,៣១** | **១៤២,៩៩** | - |
| **II-ចម្ការកៅស៊ូកសិឧស្សាហកម្មឯកជន** | | | | | |
| ១ | ក្រុមហ៊ុន សុកគិរីកា អ៊ិនវេសមេន គ្រុប | ៩.៣៥៦,៨៨ | ៦.៦៨៩,៤៤ | ៤.៦៨៩,៤៩ | ៩៩៤,៧២ |
| ២ | ក្រុមហ៊ុន ស៊ីហ្វូវ៉ាប់ប៊េលីមីធីត (រតនគិរី) | ៨៦៧,៩៤ | ១.៦២៥,៩០ | ៣៨៨,៨៤ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ៨៨៥,០១ | ៣១០,២៩ | ១០០,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.០៥៦,៣២ | ៣.២៦៦,៩២ | ១.៣៥០,៥០ | ៧៩១,០០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៩៥,៥៨ | ៥.២៥៩,០៨ | ១.៥២០,៣២ | ២០១,៦០ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វូវីសសស៍ (ស្នួល) | ១.៦២៣,២០ | ២.៨២៤,៤១ | ៤៩២,២៩ | ២០០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.១៧៧,០៤ | ១.១៥៩,០០ | ៣៦២,៣០ | ៣៤,០០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ២.១៣៥,២៩ | ៣.៦៨៧,៥៣ | ៥២១,១៧ | ៣៦,០០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (រមាសហែក) | - | ១.៥៧០,៦៣ | - | - |
| ១០ | ក្រុមហ៊ុនក្រែក (ខេមបូឌា) ខូអិលធីឌី | ២.៨៥២,៧២ | ២.៦១៨,៧៥ | ១.៤៨៨,១០ | - |
| | **សរុប II** | **២៥.៦០៦,៧៧** | **២៩.៥៨៦,៦៧** | **១១.១២៣,៣០** | **២.៣៥៧,៣២** |
| **III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច** | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | ១៣៥.៤៤៦,០០ | | |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រូសារ | ៥២.៥០៥,០០ | ៨៤.៩០១,០០ | | ១០.៦៥០,០០ |
| | **សរុប III** | **៥២.៥០៥,០០** | **២២០.៣៤៧,០០** | **១០.៦៥០,០០** | **១០.៦៥០,០០** |
| | **សរុប I+II+III** | **៧៨.៥០៩,២៩** | **២៥០.២៧៧,៩៨** | **២១.៩១៦,២៩** | **១៣.០០៧,៣២** |

### ២.២ ការផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-បើកវគ្គបណ្តុះបណ្តាលស្តីពីការដាំដុះនិងថែទាំកៅស៊ូនៅស្ថានីយក្នុងស្រុកត្បូងឃ្មុំ ខេត្តត្បូងឃ្មុំ។

### ២.៣ ការស្រាវជ្រាវអំពីការបន្ថាត់ពូជ

-បំបៅកូនកៅស៊ូបានចំនួន១.២២៤ដើម សម្រាប់ដាំជួសឡូត៍ពិសោធន៍ក្លូនកៅស៊ូចំនួន៨ នៅក្រុមហ៊ុនចម្ការកៅស៊ូក្រែក ខេមបូឌា ស្ថិតនៅស្រុកស្វាយលើ ខេត្តសៀមរាប។

### ២.៤ ការស្រាវជ្រាវអំពីសរីរវិទ្យានិងអាជីវកម្ម

-វាស់ទំហំដើម តាមដានការលូតលាស់ចម្ការពិសោធន៍ចម្ការកៅស៊ូក្រែក និងត្រួតពិនិត្យជំងឺស្ងួតមុខចៀរចម្ការពិសោធន៍ក្នុងស្ថានីយអនុវត្ត។

### ២.៥ ការស្រាវជ្រាវ ការដាំដុះ និងការពារ

-តាមដាននិងត្រួតពិនិត្យគ្រប់ចម្ការពិសោធន៍ ស្រង់ទិន្នន័យឧតុនិយមទឹកភ្លៀងលើដំណាំកៅស៊ូ។

### ២.៦ ការងារក្នុងមន្ទីរពិសោធន៍យថាប្រភេទ

-ធ្វើតេស្តអន្តរមន្ទីរពិសោធន៍លើកទី១១០ ជាមួយIRA ដើម្បីទទួលស្គាល់ជាមន្ទីរពិសោធន៍យោងនៅក្នុងតំបន់ចំពោះកៅស៊ូ TSR ។

### ២.៧ ការងារនៅស្ថានីយអនុវត្ត

-បំបៅកូនកៅស៊ូបានចំនួន៩ពូជ ស្មើនឹង៨.៦៣៨ដើម និងថែទាំកៅស៊ូមិនទាន់ឲ្យផលចំនួន១៨៧,៥០ហិកតា។

## ៣ ផ្នែកផលិតកម្មនិងបសុពេទ្យ

### ៣.១ ការងារស្ថានីយពិសោធន៍ពូជជ្រូក-គោ

-ជ្រូកសរុបចំនួន៣៩១ក្បាល ក្នុងនោះជ្រូកបាចំនួន១២ក្បាល ជ្រូកមេចំនួន១១៧ក្បាល និងកូនជ្រូកចំនួន២៦២ក្បាល

-គោសរុបចំនួន២០២ក្បាល ក្នុងនោះគោបាចំនួន៤ក្បាល គោមេប្រាម៉ាន់កាត់ចំនួន៦២ក្បាល គោជំទង់ចំនួន៥៣ក្បាល គោបៅដោះចំនួន៤៥ក្បាល គោកំផែងសែនចំនួន៣៨ក្បាល និងមេគោចាស់ងាប់ចំនួន២ក្បាលនិងកូនគោកើតថ្មីចំនួន១ក្បាល។

### ៣.២ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុពេទ្យ

-ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម ជំងឺសារទឹក ជំងឺបូសខ្យល់ និងជំងឺប៉េស្តជ្រូក

-រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

-អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅរាជធានី ខេត្ត

-ផ្នែកពិនិត្យវត្ថុវិភាគសរុបចំនួន១.២៥២សំណាក

-ផ្នែកសរីរោគសាស្រ្តសរុបចំនួន៣៨ក្បាល ។

### ៣.៣ ការអនុវត្តវិធានបសុពេទ្យ

-សេចក្តីព្រាងច្បាប់ស្តីពីសុខភាពសត្វនិងផលិតកម្មសត្វ ប្រជុំពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រីកម្រិតអន្តរក្រសួងចំនួន២លើក

-ទទួលទូរស័ព្ទហៅចូលសរុបចំនួន៣៥ករណី មកពីតាមបណ្តារាជធានី ខេត្ត វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា និងក្រសួងសុខាភិបាល សាកសួរពីរោគសញ្ញា វិធានការការពារ ការធ្វើជីវសុវត្ថិភាព រាយការណ៍ពីបក្សីឈឺ ងាប់ និងករណីមនុស្សឈឺជំងឺផ្តាសាយបក្សី

-ក្នុងត្រីមាសទី១ ឆ្នាំ២០១៨នេះ មានករណីផ្ទុះជំងឺផ្តាសាយបក្សីប្រភេទ H5N1 ចំនួន៤ករណីគឺៈ នៅក្នុងភូមិស្វាយព្រៃ ឃុំសណ្តែក ស្រុកបាធាយ ខេត្តកំពង់ចាម ភូមិពាមល្វា ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ភូមិទួលសង្កែ ឃុំកំពុងកុង ស្រុកកោះធំ ខេត្តកណ្តាល និងវិទ្យាស្ថានជាតិស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ធ្វើការទប់ស្កាត់ចលនាបក្សីនិងផលិតផលបក្សីដែលនាំចូលពីប្រទេសជិតខាង ដោយបានណែនាំប្រជាពលរដ្ឋនិងអាជីវករឲ្យយល់ដឹងពីផលវិបាកដែលបណ្តាលមកពីជំងឺផ្តាសាយបក្សី ។

### ៣.៤ ការងារឡជីវឧស្ម័ន

-ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន

-ផលិតឡជីវឧស្ម័នសរុបចំនួន៣១០ឡ។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារចំណូលព្រៃឈើ

-ចំណូលពីផលព្រៃឈើចូលថវិកាជាតិសរុបចំនួន២៦.៩២៧.៥១៥.០៨៩រៀល និងផ្តល់សេវាសាធារណៈចំនួន៥.៥៤៦.៨៤១.៨៣០រៀល។

### ៤.២ ការងារព្រៃឈើនិងសហគមន៍ព្រៃឈើ

-ធ្វើសារពើភ័ណ្ឌវាយតម្លៃប៉ាន់ស្មានធនធានព្រៃឈើជូនក្រុមហ៊ុនចំនួន០៦

-ផ្តល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជន៖ ឈើហ៊ុបមូលសរុបចំនួន ៣៧.០៨៦ម៣ ឈើអារចំនួន២៤៨ម៣ ឈើជ្រុងចំនួន៣.៨៥២ម៣ កូនឈើចំនួន៩១៥.៦៩៤ដើម អុសចម្រុះចំនួន៨.៦៣៨ស្ទែរ សសរមូលចំនួន១.៣៤៥ដើម ឫស្សីចំនួន៦៤២តោន និងជ័រទឹកចំនួន៨០តោន។

### ៤.៣ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

-ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(បឹងព្រែកល្ពៅ តំបន់អភិរក្សអន្លង់ព្រីង តំបន់អភិរក្សអាងត្រពាំងថ្ម និងតំបន់អភិរក្សសត្វខ្សឹបកំពង់ធំ-សៀមរាប)ដែលមានសត្វស្លាបចំនួនប្រមាណ២០៨ប្រភេទ ស្មើនឹងជាង៣៥.២៤៧ក្បាល

-រៀបចំអាហារដ្ឋានត្មាតចំនួន០៦លើក នៅតំបន់ព្រៃការពារមណ្ឌលគិរី តំបន់អភិរក្សជីវចម្រុះសៀមប៉ាង ស្ទឹងត្រែង និងក្រចេះ ដោយរាប់ឃើញត្មាតសរុបជាង១២០ក្បាល

-ការពារសម្បុកត្រយ៉ងចង្កំកសចំនួន២៣ ត្មាតចំនួន១១ រំពេទន្លេចំនួន៧ និងត្រដក់តូចចំនួន៩៦ នៅតំបន់សៀមប៉ាងភាគខាងលិច តំបន់ព្រៃការពារព្រះវិហារ និងតំបន់ទន្លេមេគង្គលើ។

### ៤.៤ ការងារអប់រំផ្សព្វផ្សាយនិងបណ្តុះបណ្តាល

-ធ្វើការអប់រំផ្សព្វផ្សាយបានចំនួន១២១លើក ច្បាប់ស្តីពីព្រៃឈើនិងលិខិតបទដ្ឋាននានាពីសារៈសំខាន់សត្វព្រៃ និងជីវចម្រុះ កិច្ចការពារសត្វព្រៃនិងជីវចម្រុះ វិធីសាស្រ្តរាប់សត្វស្លាប ការពារសម្បុកសត្វ លិខិតបទដ្ឋាននានាទាក់ទងដល់វិស័យព្រៃឈើនិងសត្វព្រៃ អនុក្រឹត្យព្រៃការពារសៀមប៉ាង ដែលមានប្រជាពលរដ្ឋចូលរួមសរុបចំនួន៣.០៩៦នាក់ ស្ត្រីចំនួន៥៦៣នាក់។

### ៤.៥ កសិដ្ឋានចិញ្ចឹម ការបង្កាត់ពូជស្វាក្ដាម និងការសង្គ្រោះសត្វព្រៃ

-ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹម និងថែរក្សាសរុបចាប់ពីដើមឆ្នាំ សត្វចំណូលថ្មីចំនួន១៩០ក្បាល សត្វកើតថ្មីចំនួន១៥ក្បាល សត្វដោះលែងចំនួន១៧០ក្បាល សត្វស្លាប់ចំនួន២៦ក្បាល ព្យាបាលសត្វចំនួន៥៩ក្បាល យកសំណាកទៅពិសោធន៍ចំនួន២០ក្បាល ធ្វើឲ្យសន្លប់ចំនួន៥៨ក្បាល ទម្លាក់សត្វល្អិតចំនួន១៤ក្បាល វះកាត់សាកសពសត្វចំនួន១៣ក្បាល ដាក់លេខកូដចំនួន២៥ក្បាល ចាក់វ៉ាក់សាំងចំនួន៣៣៧ក្បាល កសាងរបងហ៊ុមព័ទ្ធនិងទ្រុងសត្វថ្មីលើចំនួន១.២០០ម២ ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៧ម២ ជួសជុលផ្លូវចំនួន២៥.៦២០ម២ សាងសង់សំណង់ផ្សេងៗចំនួន៨ម២ ស្តារអនាម័យព្រៃចំនួន១៤៣.៣៤៦ម២ ដាំកូនឈើចំនួន៣.៧០០ដើម បណ្តុះផ្កាលម្អ(ផ្កាក្រដាស)ចំនួន៦.១៩៧ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន២.០៩៥នាក់

-ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្ដាមមេ-បាពូជ និងកូនស្វាក្ដាមចំនួន៥៦.៥៤៧ក្បាល។

### ៤.៦ គម្រោងអភិរក្សសត្វក្រពើកម្ពុជា អភិរក្សធនធានសេនេទិច និងប្រភេទគ្រាប់ពូជ

-ថែរក្សាកូនក្រពើចំនួន២៦ក្បាលដែលយកពីស្ទឹងអារ៉ែង ឃុំជំនាប់ ស្រុកថ្មបាំង ខេត្តកោះកុង មកថែបំប៉ននៅស្នាក់ការល្បាតអារ៉ែងរបស់រដ្ឋបាលព្រៃឈើក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ខេត្តកោះកុង រង់ចាំការដោះលែងចូលបឹងធម្មជាតិនៅចុងឆ្នាំ២០១៤ និងដោះលែងក្រពើបង្កាត់ពូជនៅសួនសត្វភ្នំតាម៉ៅចំនួន០៨ក្បាល

-បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងក្នុងឃុំថ្មដូនពៅ ស្រុកថ្មបាំង ឆាយរាបក្នុងឃុំដងពែង ស្រុកស្រែអំបិល តំបន់ស្តារក្រពើក្នុងឃុំតាតៃលើ ស្រុកថ្មបាំង ខេត្តកោះកុង និងអូរសោម ឃុំអូរសោម ស្រុកវាលវែង ខេត្តពោធិ៍សាត់

-តាមដានសត្វក្រពើដែលបានដោះលែង១៥ក្បាល តាមរយៈឧបករណ៍វិទ្យុសំឡេងដោយបានឃើញក្រពើ០៧ក្បាល

-បន្តការចុះស្រាវជ្រាវពូជឈើនៅខេត្តសៀមរាបនិងខេត្តកំពង់ធំ និងថែទាំចម្ការពូជឈើនៅខេត្តព្រះសីហនុនិងស្វាយរៀង។

### ៤.៧ ការងារដាំដើមឈើ

-ស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើចំនួន០៤របស់រដ្ឋបាលព្រៃឈើ បណ្តុះកូនឈើសម្រាប់ដាំជាចម្ការបានចំនួន ៤៣៥.០០០ដើម ឈូសឆាយដីព្រៃបានចំនួន១៥៥ហិកតា និងស្ថានីយដាំឈើចំនួន១០មានចម្ការឈើចាស់ចំនួន ៣.៣១៨ហិកតា

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Think Biotech(Cambodia) Co., Ltd បានកាប់ឆ្ការនិងឈូសឆាយសម្អាតដីចំនួន១.៣៦២ហិកតា និងបណ្តុះកូនឈើចំនួន១០០.០០០ដើម

-ការដាំឈើដៃគូជាមួយក្រុមហ៊ុន Oji (Cambodia) Plantation បានឈូសឆាយសម្អាតដីចំនួន៣៨៤ហិកតា និងបណ្តុះកូនឈើចំនួន១៥០.០០០ដើម

-ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានឈូសឆាយដីចំនួន៨៥០ហិកតា

-ថ្នាលបណ្តុះកូនឈើរបស់រដ្ឋបាលព្រៃឈើអនុវត្តៈ បណ្តុះកូនឈើគ្រប់ប្រភេទចំនួន១.៦៤៣.១៤០ដើម និងចែកចាយកូនឈើបានចំនួន៥.៥២១ដើម

-ដំណាំកសិរុក្ខកម្ម មានឡូត៍ស្រាវជ្រាវប្រព័ន្ធកសិរុក្ខកម្មទំហំ៥ហិកតា ដែលមានទីតាំងនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ។

### ៤.៨ ការងារសហគមន៍ព្រៃឈើ

-ធ្វើបច្ចុប្បន្នភាពទិន្នន័យសហគមន៍ព្រៃឈើក្នុងខណ្ឌរដ្ឋបាលព្រៃឈើពោធិ៍សាត់ចំនួន១១សហគមន៍ ដែលមានផ្ទៃដីសរុបចំនួន២.៥៣៩ហិកតា

-ខណ្ឌរដ្ឋបាលព្រៃឈើព្រះវិហារបានចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ចំនួន១០កន្លែង ដែលមានផ្ទៃដីចំនួន ១៧.៧១៦ហិកតា ស្ថិតក្នុងខេត្តព្រះវិហារ។

### ៤.៩ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

#### ៤.៩.១ ការងារពាណិជ្ជកម្មនាំចេញ នាំចូល

-ផ្តល់អាជ្ញាប័ណ្ណនាំចេញផលិតផលឈើជ្រុងកែច្នៃមានទោល ឬបន្ទះអតិបរមា២៥ស.ម និងឈើដាំប្រភេទអាកាស្យាកាត់ជាកង់ៗ និងឈើអាកាស្យាអារកែច្នៃជូនក្រុមហ៊ុនចំនួន០៣ ដែលមានបរិមាណឈើសរុបចំនួន៣០.៣១៣,២១៨ម៣ ឈើអាកាស្យាកាត់ជាកង់ៗចំនួន៥០០ស្ទែរ និងឈើអាកាស្យាអារកែច្នៃចំនួន២០០ម៣

-ផ្តល់អាជ្ញាប័ណ្ណនាំចេញផលិតផលកែច្នៃចំនួន០១ក្រុមហ៊ុន សរុបចំនួន១.០០១,១០៦ម៣។

#### ៤.៩.២ ការងារឧស្សាហកម្ម

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញជូនក្រុមហ៊ុនចំនួន០២ ស្មើនឹង១៥៣សន្លឹក ដែលមានបរិមាណឈើចំនួន២៣.៩៨១,០៨៧ម៣

-ផ្តល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចូលជូនក្រុមហ៊ុនចំនួន០១ ស្មើនឹង០៣សន្លឹក ដែលមានបរិមាណឈើចំនួន១៥៤ម៣។

### ៤.១០ ការងារនីតិកម្មនិងវិវាទ

-បង្ក្រាបបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្ទ្រានដីព្រៃដោយបញ្ជូនទៅតុលាការសរុបចំនួន ៥៣៣ករណី

-ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៣៩៥,០៤៨ម៣ ឈើអារចំនួន ៩១៧,៩៧១ម៣ ឈើក្រាក់គ្រញូងចំនួន៥២,០៣៨ម៣ និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត ព្រមទាំងដកហូតដីព្រៃឈើចំនួន១០១,៥៩១ហិកតា

-ចុះស្រង់ស្ថិតិដីព្រៃឈើដែលបានកាប់រានសរុបចំនួន២២,៥០២ហិកតា ។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

៥.១.១ នេសាទទឹកសាប

-ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៣-២០១៤ សរុបបានចំនួន១៩.០០០តោន ស្មើ១២៦,៦៧% នៃផែនការ ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.៥០០តោន

-នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៤ សរុបបានចំនួន១២០.០០០តោន ស្មើ៣០,៧៧% នៃផែនការ ៣៩០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥០.០០០តោន

-នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៤ សរុបបានចំនួន៣៥.០០០តោន ស្មើ១៩,៤៤% នៃផែនការ ១៨០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១០.០០០តោន ។

**៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៣**

-អនុវត្តបានចំនួន២៦.៥០០តោន ស្មើ២៤,០៩% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន១.៥០០តោន។

### ៥.២ វារីវប្បកម្ម

-ការចិញ្ចឹមត្រីនិងបង្គា សរុបបានចំនួន២២.០០០តោន ស្មើ២២% នៃផែនការ១០០.០០០តោន ប្រៀបធៀប រយៈពេលដូចគ្នា កើនឡើងចំនួន៤.០០០តោន

-ការចិញ្ចឹមក្រពើ សរុបបានចំនួន៣៥.០០០ក្បាល ស្មើ១១,៦៧% នៃផែនការ៣០០.០០០ក្បាល ប្រៀបធៀប រយៈពេលដូចគ្នា កើនឡើងចំនួន១២.០០០ក្បាល

-ការភ្ញាស់កូនត្រីពូជ សរុបបានចំនួន២៣.០០០.០០០កូន ស្មើ១៤,៣៨% នៃផែនការ១៦០.០០០.០០០កូន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៧.០០០.០០០កូន។

### ៥.៣ ការកែច្នៃផលនេសាទ

-ផលនេសាទទឹកសាបក្នុងរដូវនេសាទ២០១៣-២០១៤ សរុបបានចំនួន២០.០០០តោន ស្មើ១៣,៣៣% នៃ ផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៥.០០០តោន

-ផលនេសាទសមុទ្រក្នុងឆ្នាំ២០១៤ សរុបបានចំនួន២.៥០០តោន ស្មើ៣១,២៥% នៃផែនការ៨.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន២០០តោន

-ការផលិតទឹកត្រី សរុបបានចំនួន១៨.០០០.០០០លីត្រ ស្មើ៣០% នៃផែនការ៦០.០០០.០០០លីត្រ ប្រៀបធៀប រយៈពេលដូចគ្នា កើនឡើងចំនួន២.០០០.០០០លីត្រ។

### ៥.៤ ការនាំចេញផលនេសាទ

-ផលនេសាទស្រស់ សរុបបានចំនួន៣.១០០តោន ស្មើ១៥,៥០% នៃផែនការ២០.០០០តោន ប្រៀបធៀបរយៈពេល ដូចគ្នា កើនឡើងចំនួន១០០តោន

-ផលនេសាទកែច្នៃ សរុបបានចំនួន១.៧០០តោន ស្មើ១៧% នៃផែនការ១០.០០០តោន ប្រៀបធៀបរយៈពេល ដូចគ្នា កើនឡើងចំនួន២០០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

-កំណត់ហេតុបទល្មើស សរុបចំនួន៧១២ករណី ដែលកើតមាននៅតំបន់ទឹកសាប៦៩៩ករណី និងតំបន់សមុទ្រ ១៣ករណី ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៩០ករណី គឺតំបន់ទឹកសាប៩៩ករណីនិងតំបន់សមុទ្រថយចុះ ៩ករណី។ ជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៦ ការប្រមូលថវិកា

-ចំណូលពីវិស័យជលផល សរុបបានចំនួន១.៤១៧.០៤០.២៥០រៀល ស្មើ៤៦,៥៧% នៃផែនការ៣.០៤២.៥០០.០០០ រៀល ប្រៀបធៀបរយៈពេលដូចគ្នា កើនឡើងចំនួន៤៣៩.៧២៩.០៥២រៀល។

## ៦ ផ្នែករដ្ឋបាល

-ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា សរុបចំនួន១.៨៨៤ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ សរុបចំនួន១.១២៥ច្បាប់ និងទទួលពីរាជធានី ខេត្ត សរុបចំនួន៣៨៥ច្បាប់

-បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត សរុបចំនួន២.២៥៦ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ សរុបចំនួន១៨៥ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ សរុបចំនួន២៥៤ច្បាប់

-ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិជាដើម ...។ល។

## ៧ ការងារសេវាកម្មនិងការគាំទ្រផ្សេងៗទៀត

-រៀបចំទិសដៅនិងផែនការសម្រាប់ការអនុវត្តឆ្នាំ២០១៤-២០១៥ដោយបានបង្ហាញពីសូចនាករធំៗ ដើម្បីសម្រួចការអនុវត្តឲ្យមានប្រសិទ្ធភាព

-រៀបចំសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨ កំពុងត្រូវបានរៀបចំឲ្យមានសង្គតភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨

-រៀបចំកសាង ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៥-២០១៧ ដែលជាមូលដ្ឋានក្នុងការរៀបចំ និងអនុវត្តថវិកាកម្មវិធីពេញលេញឆ្នាំ២០១៥ និងការរៀបចំនូវអង្គភាពថវិការបស់ក្រសួង សំដៅឆ្លើយតបទៅនឹងកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលកម្ពុជា

-បានរៀបចំបូកសរុបការងារបង្កបង្កើនផលដំណាំរដូវប្រាំង និងរៀបចំទិន្នន័យស្ថិតិកសិកម្មឆ្នាំ២០១៣-២០១៤

-ផ្សព្វផ្សាយព័ត៌មានតម្លៃទីផ្សារកសិកម្មជាប្រចាំតាមរយៈវិទ្យុ ព្រឹត្តិបត្រប្រចាំខែនិងគេហទំព័រ WWW.agricultural market information.org.kh

-បានរៀបចំក្រុមចម្រុះរបស់ក្រសួង និងបានចុះត្រួតពិនិត្យជាក់ស្តែងដល់ទីតាំងក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីពិនិត្យវាយតម្លៃលើការអនុវត្តកិច្ចសន្យាវិនិយោគសម្រាប់ឆ្នាំ២០១៣និងត្រីមាសទី១ឆ្នាំ២០១៤

-បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការរៀបចំអនុវត្តថវិកាកម្មវិធីពេញលេញ ការបង្កើតអង្គភាពថវិកា និងការពិនិត្យឡើងវិញនូវកំណត់អនុកម្មវិធីសូចនាករចង្កោមសកម្មភាព និងការវិភាគថវិកាដើម្បីឲ្យស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម២០១៤-២០១៨

-ទំនាក់ទំនងនិងសហការជាមួយអង្គការជាតិនិងអន្តរជាតិ ដើម្បីទទួលបានជំនាញការមកជួយរៀបចំយន្តការអនុវត្តអនុក្រឹត្យស្តីពីផលិតកម្មកសិកម្មតាមកិច្ចសន្យា

-បានរៀបចំសន្និបាតកសិករ និងសន្និបាតកសិកម្មទូទាំងប្រទេស

-ខិតខំពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការជាតិ និងអន្តរជាតិ កសាងគម្រោងនិងផែនការសកម្មភាពនានាស្វែងរកជំនួយនិងការគាំទ្រពីបណ្តាប្រទេសនិងដៃគូផ្តល់ជំនួយក្នុងការអភិវឌ្ឍន៍វិស័យកសិកម្ម ដើម្បីចូលរួមការអនុវត្តគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ការរៀបចំប្រជុំក្នុងប្រទេសក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការផ្សេងៗ។

## ៨ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

-ចូលរួមប្រជុំនិងសិក្ខាសាលាផ្សេងៗ នៅក្នុងប្រទេសសរុបចំនួន៥៦លើក និងនៅប្រទេសថៃ នេប៉ាល់ និងវៀតណាម សរុបចំនួន៣លើក

-ទទួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូអន្តរក្រសួងនៃប្រទេសបង់ក្លាដេសចំនួន៦រូប ដែលដឹកនាំដោយ Mr. Md. Hemayet Uddin Deputty Secretary នៃក្រសួងកសិកម្មប្រទេសបង់ក្លាដេស ដើម្បីពិភាក្សាការងារស្តីពីផលិតភាពដំណាំកសិកម្មនៅក្នុងប្រទេសកម្ពុជា

-ទទួលជួបធ្វើបទបង្ហាញអំពីលទ្ធផលការងារពិសោធន៍ស្រាវជ្រាវនិងពិភាក្សា ព្រមទាំងផ្តល់ប្រឹក្សាចំនួន១៨លើក ជាមួយគណៈប្រតិភូភ្ញៀវជាតិនិងអន្តរជាតិចំនួន៨០នាក់

-ធ្វើពិសោធន៍ចំនួន៥៧ប្រភេទ នៅ២៣៦កន្លែង ក្នុងនោះមានពិសោធន៍បន្សាំពូជលើស្រែកសិករនិងស្រែបង្ហាញ ចំនួន១១៩កន្លែង

-ធ្វើអង្កេតបានចំនួន៥ប្រភេទ ដោយសម្ភាសន៍កសិករចំនួន៥០០គ្រួសារ

-ធ្វើការបែងចែកសៀវភៅឯកសារនានាចំនួន៣៦២ច្បាប់និងព្រឹត្តិបត្រព័ត៌មានកសិករចំនួន៧១៤ច្បាប់ ជូនថ្នាក់ដឹកនាំ ក្រុមប្រឹក្សាភិបាល អង្គភាពក្រោមឱវាទក្រសួង មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្មស្រុក និងអ្នកពាក់ព័ន្ធ ជាពិសេសដល់កសិករ

-បន្តការអភិរក្សពូជដំណាំដែលមាននៅក្នុងធនាគារពូជ នៅក្នុងផ្ទះសំណាញ់ និងនៅក្នុងចម្ការ លើដំណាំចំនួន ៣០ប្រភេទ ក្នុងនោះស្រូវចំនួន៥.៩៦០បញ្ជីក/សំណាក និងដំណាំផ្សេងៗចំនួន២៩ប្រភេទរួមមាន៩៦៥បញ្ជីក/សំណាក សរុបទាំងអស់ចំនួន៦.៩២៥បញ្ជីក/សំណាក

-រៀបចំសម្អាត សម្ងួត វេចខ្ចប់ទុកដាក់សំណាកស្រូវក្រោយធ្វើយុវកម្ម និងការវាយតម្លៃសរុបចំនួន២៦៥បញ្ជីក/ សំណាក

-ចូលរួមជាវាគ្មិនក្នុងកម្មវិធីវិទ្យុ និងទូរទស្សន៍៖ ទទួលសម្ភាសន៍ និងថតជាខ្សែវីដេអូខ្លីជាមួយស្ថានីយទូរទស្សន៍ NPK របស់ប្រទេសជប៉ុន ដែលទាក់ទងនឹងស្ថានភាពទូទៅនៃផលិតកម្មដំណាំស្រូវនៅក្នុងប្រទេសកម្ពុជា និងកិច្ចអន្តរាគមន៍មួយចំនួន ដើម្បីចូលរួមក្នុងការជំរុញឲ្យសម្រេចបាននូវផែនការនាំចេញអង្ករឲ្យបាន១លានតោននៅក្នុងឆ្នាំ២០១៥ ដោយផ្តោតជាពិសេសលើការអភិវឌ្ឍវិស័យផលិតកម្មគ្រាប់ពូជសុទ្ធ

-ការស្រាវជ្រាវរកព័ត៌មានបច្ចេកទេសកសិកម្មក្នុងគេហទំព័រ www.cardi.org.kh និង www.crkb.org.kh មានអ្នកចូលរួមសរុបចំនួន៩០.០០០នាក់ គិតជាមធ្យមប្រមាណ១.០០០នាក់ក្នុងមួយថ្ងៃ។

## ៩ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ៩.១ សាលាជាតិកសិកម្មព្រែកលៀប

**និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៣-២០១៤ សរុបចំនួន១.៥១២នាក់(ស្រី៤៤៧នាក់)ក្នុងនោះ៖**

-និស្សិតអាហារូបករណ៍(ទូទៅ)ចំនួន១.១០៤នាក់ ក្នុងនោះស្រី៤០៨នាក់

-និស្សិតបង់ថ្លៃចំនួន១៨៤នាក់ ក្នុងនោះស្រី៣១នាក់

-និស្សិតបណ្តុះបណ្តាលបន្តថ្ងៃសៅរ៍-អាទិត្យចំនួន២២៤នាក់ ក្នុងនោះ ស្រី៣៨នាក់។

### ៩.២ សាលាជាតិកសិកម្មកំពង់ចាម

**និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១២-២០១៣ សរុបមានចំនួន១.៥៥៩នាក់(ស្រី៦០៨នាក់)ក្នុងនោះ៖**

-និស្សិតអាហារូបករណ៍សរុប១.២៩៥នាក់(ស្រី៥៣៥នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៩១៣នាក់ (ស្រី៣៣៩នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម៣៨២នាក់(ស្រី១៩៦នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ

-និស្សិតសិក្សាបង់ថ្លៃ២៦៤នាក់ (ស្រី៧៣នាក់) ថ្នាក់បរិញ្ញាចំនួន២៥២នាក់(ស្រី៧៣នាក់) និងថ្នាក់បរិញ្ញារងចំនួន ១២នាក់(ស្រី០នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។

### ៩.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម

-និស្សិតដែលកំពុងសិក្សាមានចំនួនសរុប៥.៩៧៣នាក់ (ស្រី១.៣៩៦នាក់) ចែកចេញជា១០មហាវិទ្យាល័យគឺ មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រ

ផលផល បច្ចេកវិទ្យានិងគ្រប់គ្រងកសិកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ កសិឧស្សាហកម្ម រៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញាវិទ្យាសាស្ត្រនិងសាលាក្រោយឧត្តម បណ្តុះបណ្តាលលើកម្មវិធីបរិញ្ញារង បរិញ្ញាបត្រ បរិញ្ញាជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ

-ចុះអនុស្សរណៈយោគយល់រវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានរបស់ប្រទេសម៉ាឡេស៊ីចំនួន៣គឺ University of Malaya, BENA និង International University of Malaya-Wales និងជាមួយ Swansea University ប្រទេសអង់គ្លេស។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួមការងារបង្កបង្កើនផលស្រូវរដូវប្រាំងសម្រេចបាន១២៦,៣៤% នៃផែនការ តិចជាងឆ្នាំមុនបើប្រៀបធៀបរយៈពេលដូចគ្នា ជាមួយនឹងការប្រមូលផលសម្រេចបាន៩៩,៧៥% នៃផ្ទៃដីអនុវត្តបាន។ ទន្ទឹមនឹងនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការយកចិត្តទុកដាក់ជំរុញការងារមុននិងក្រោយពេលប្រមូលផល រៀបចំរក្សាទុកដាក់ផលស្រូវឲ្យបានល្អ ដើម្បីធានាសន្តិសុខស្បៀងក្នុងគ្រួសារនិងការលៃទុកពូជ។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅតែបន្តចាត់វិធានការនិងបន្តពិនិត្យតាមដានដើម្បីទប់ស្កាត់ការរាលដាលជំងឺផ្តាសាយបក្សី និងជំងឺឆ្លងសត្វពីតំបន់មួយទៅតំបន់មួយទៀត។

## V- ទិសដៅ

-បន្តតាមដានជំរុញការប្រមូលផលស្រូវរដូវវស្សាឲ្យបានល្អ និងវាយតម្លៃទិន្នផល និងបរិមាណផលទទួលបានឲ្យបានច្បាស់លាស់

-សហការជាមួយអាជ្ញាធរដែនដីធ្វើការអប់រំផ្សព្វផ្សាយដល់ប្រជាកសិករឲ្យយកចិត្តទុកដាក់ជំរុញការងារមុនប្រមូលផល និងក្រោយពេលប្រមូលផលស្រូវ ដោយត្រូវប្រមូលផ្តុំរក្សាទុកដាក់ក្នុងជង្រុកឱ្យបានល្អតាមបច្ចេកទេសដើម្បីធានាសន្តិសុខស្បៀងក្នុងគ្រួសារផង និងការលៃទុកពូជផង

-តាមដានជាប់ជាប្រចាំនូវដំណើរការបង្កបង្កើនផលស្រូវប្រាំង ដើម្បីណែនាំជំរុញការដាំដុះនៅតំបន់ដែលមានប្រភពទឹកស្រោចស្រពគ្រប់គ្រាន់ ដោយសហការជាមួយមន្ទីរធនធានទឹក និងអាជ្ញាធរមូលដ្ឋាន សម្របសម្រួលបែងចែកការប្រើប្រាស់ទឹកស្រោចស្រព និងអន្តរាគមន៍បូមបាចតាមស្ថានភាពជាក់ស្តែង និងចាំបាច់។ សម្រាប់ស្រូវរដូវប្រាំងត្រូវបន្តផ្សព្វផ្សាយឲ្យកសិករប្រើប្រាស់ពូជល្អមានទិន្នផលខ្ពស់ ជាពិសេសពូជ IR 66 ពូជផលសារ។ល។

-តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុ

-តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា

-បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអតុល្យភាពស្បៀង (អង្គរ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាសដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក លើតំបន់ដីដែលនៅមានសំណើមអាចដាំដុះបាន បន្ទាប់ពីប្រមូលផលស្រូវវស្សា ដើម្បីបានផលកម្រៃបន្ថែមដល់សេដ្ឋកិច្ចគ្រួសារ

-បន្តអប់រំផ្សព្វផ្សាយ និងជួយដល់ប្រជាកសិករក្នុងការតម្កល់និងរក្សាទឹកសម្រាប់ប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃនិងការបង្កបង្កើនផល

-បន្តអប់រំផ្សព្វផ្សាយដល់ប្រជាកសិករដែលធ្វើស្រូវចម្ការឱ្យប្តូរពូជស្រូវដើម្បីបង្កើនទិន្នផលនិងយកចិត្តទុកដាក់ជំរុញការប្រុងប្រយ័ត្នបង្ការភ្លើងឆេះស្រូវជាយថាហេតុក្នុងរដូវប្រាំងនេះ

-ពិនិត្យ និងពង្រឹងឡើងវិញនូវមធ្យោបាយនិងសម្ភារផ្សេងៗដើម្បីត្រៀមលក្ខណៈជួយអន្តរាគមន៍មានដូចជា៖ ស្រូវពូជនិងពូជបន្លែ មធ្យោបាយនានាសម្រាប់អន្តរាគមន៍ដល់គ្រោះរាំងស្ងួត (អន្តរាគមន៍បូមបាច) និងមធ្យោបាយ សម្ភារនានាដើម្បីទប់ទល់ជំងឺសត្វនិងជំងឺឬសត្វចង្រៃបំផ្លាញដំណាំ។ល។

-ការបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ក៏ដូចជាការរៀបចំគំរូការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិពាណិជ្ជកម្ម

-អង្កេតទូទៅស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍ក្លូនកៅស៊ូនិងត្រួតពិនិត្យជំងឺកៅស៊ូ

-ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

-រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត

-ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

-ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សីនិងជំងឺផ្តាសាយ (A) H1N1

-ពង្រឹងទប់ស្កាត់ចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

-ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

-ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត

-ជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការនិងតាមការពិន័យអន្តរការណ៍

-បន្តតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រសិទ្ធភាពនៃកម្មវិធី ដោយលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ និងការពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីចំនួន១០០កន្លែងបន្ថែមទៀត

-បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ

-បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើសត្វព្រៃតាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពស្រាវជ្រាវ

-កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

-បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់

-រៀបចំសេចក្តីណែនាំនិងដាក់ឲ្យប្រើប្រាស់សៀវភៅកត់ត្រាឈើចេញចូលតាមរោងសន្និធិផល អនុផលព្រៃឈើ

-ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងវិស័យជលផល

-រៀបចំបោះបង្គោលបេតុងចំនួន១៥០បង្គោលនិងសាងសង់ស្នាក់ការល្បាតចំនួន១៦កន្លែងនៅកន្លែងអភិរក្សជលផល

-បន្តពង្រឹងសមត្ថភាពសហគមន៍នេសាទ

-រៀបចំនិងអនុវត្តវិធានការការពារដែននេសាទនិងធនធានជលផល

-បន្តស្រាវជ្រាវដកហូតនិងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

-រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

-បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

-ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៤ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ការកែច្នៃផលនេសាទទឹកសាប ការកែច្នៃផលនេសាទសមុទ្រ ការផលិតទឹកត្រី) ការនាំចេញផលនេសាទនិងការបង្កើនផលចំណូលថវិកាជាតិ

-បន្តរៀបចំទិវាមច្ឆជាតិ១កក្កដានិងរុក្ខទិវា៩កក្កដារៀងរាល់ឆ្នាំ សំដៅបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃធនធានជលផលនិងព្រៃឈើ

-ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២

-បន្តជំរុញការត្រួតពិនិត្យ និងតាមដានការបង្ក្រាបបទល្មើសនេសាទ

-បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ស្តីពីថ្នាំកសិកម្មនិងជីកសិកម្ម

-ពង្រឹងការងារបញ្ជិកាគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មរាជធានី-ខេត្ត ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីនៅឆ្នាំ២០១៥

-បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមវិស័យទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ

-បន្តចុះពិនិត្យផ្ទាល់ដល់ទីវាលរបស់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់និងការប្រមូលចំណូលបង់ចូលថវិកាជាតិ

-បន្តយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវនិងកសាងគោលការណ៍លិខិតបទដ្ឋានណែនាំជាសារាចរ សេចក្តីណែនាំអំពីការងារគ្រប់គ្រងមន្ត្រីរាជការ និងរៀបចំបែបបទការអនុវត្តជាក់ស្តែងក្នុងការគ្រប់គ្រងធនធានមនុស្សឲ្យល្អប្រសើរតាមប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា ដោយចងក្រងតាមកម្រិតសញ្ញាបត្រ មុខជំនាញ និងតាមមុខតំណែង

-ត្រៀមរៀបចំកិច្ចប្រជុំលើកទី៣៥ នៃរដ្ឋមន្ត្រីកសិកម្មនិងព្រៃឈើអាស៊ាន ព្រមទាំងកិច្ចប្រជុំអមមួយចំនួនទៀតនិងធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំស្តីពីវិស័យកសិកម្មនិងព្រៃឈើអាស៊ានឆ្នាំ២០១៤ ធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី១០ ស្តីពីបណ្តាញត្រួតពិនិត្យអាស៊ានលើចំណីអាហារដែលមានប្រភពពីផលិតផលបម្រែបម្រួលហ្សែន និងត្រៀមចូលរួមកិច្ចប្រជុំកំពូល ACMECS លើកទី៥ និងCLMV លើកទី៦

-ពង្រឹងការគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាការអនុវត្តអនុសាសន៍ប្រកបដោយគតិបណ្ឌិតរបស់ តេជោសែន អំពីការដំឡើងកាំប្រាក់មន្ត្រីរាជការឲ្យបានលឿនដើម្បីលើកទឹកចិត្តដល់មន្ត្រីរាជការឲ្យខិតខំប្រឹងប្រែងធ្វើការប្រកបដោយប្រសិទ្ធភាព

-បន្តរៀបចំលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំនិងសិទ្ធិអ្នកបង្កាត់ពូជដំណាំ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្ម ច្បាប់ស្តីពីសហគមន៍កសិកម្ម ដើម្បីធានាដល់ប្រសិទ្ធភាពពេញលេញក្នុងការអនុវត្ត

-បន្តរៀបចំច្បាប់ផ្សេងៗទៀតតាមផ្នែកនីមួយៗតាមការចាំបាច់ ដូចជាច្បាប់ស្តីពីកៅស៊ូ ច្បាប់ស្តីពីការគ្រប់គ្រងដីកសិកម្ម ច្បាប់ស្តីពីសត្វព្រៃនិងជីវចម្រុះ ច្បាប់ស្តីពីគុណភាព និងសុវត្ថិភាពផលិតផលកសិកម្មដើម្បីធានាដល់ដំណើរការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទឲ្យបានសមស្រប៕

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ៣ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

បណ្ឌិត អ៊ុក រ៉ាប៊ុន